UNITED NATIONS
CAMBODIA

# សុខភាព និងការឆ្លើយតបចំពោះជំងឺកូវីដ ១៩

## ឯកសារព័ត៌មានទី ១៤

## ថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០២១

ការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ នៅប្រទេសកម្ពុជា បានបង្កការរំខានដល់គ្រប់ទិដ្ឋភាពទាំងអស់នៃសង្គម រាប់បញ្ចូលទាំងសុខមាលភាពផ្លូវកាយ ផ្លូវចិត្ត និងសង្គមរបស់សហគមន៍ផងដែរ។ កន្លងមក មានការរាយការណ៍ពីការឆ្លងជំងឺនេះជាង ១១៥.៣៣៥ ករណី និងមានការបាត់បង់ជីវិតចំនួន ២.៥៤៤ ករណី។ បញ្ហាប្រឈមក្នុងការឆ្លើយតបចំពោះការរាតត្បាតជាសកលកើតមានស្រដៀងៗគ្នានៅតាមប្រទេសនានា ដូចជា ការលេចឡើងនូវពពួកវីរុសបំប្លែងថ្មី ដែលកាន់តែងាយឆ្លងជាមុន ការឆ្លងក្នុងចំណោមមនុស្សពេញវ័យ និងវ័យក្មេង ដែលមានសុខភាពមាំមួន និងដែលតែងតែចល័តពីទីកន្លែងមួយ ទៅទីកន្លែងមួយទៀត ដែលធ្វើឱ្យគេពិបាករកឃើញ និងទប់ស្កាត់វីរុសនេះ ការលំបាកក្នុងការគោរពឱ្យបានពេញលេញតាមវិធានការសុខភាពសាធារណៈ និងវិធានការសង្គម ដែលមានជាធរមាន ភាពនឿយណាយនឹងការរាតត្បាតជាសកល ការមានគំនិតសុទិដ្ឋិនិយមចំពោះវ៉ាក់សាំងការពារជំងឺនេះ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមទាំងនេះក៏នាំមកនូវកាលានុវត្តភាព សម្រាប់ប្រព័ន្ធសុខាភិបាលនៅកម្ពុជា និងប្រព័ន្ធផ្សេងទៀតផងដែរ។ ការវិនិយោគលើកាលានុវត្តភាពទាំងនេះនឹងផ្តល់នូវផលសាយភាយរាប់ឆ្នាំទៅមុខទៀត។

រាជរដ្ឋាភិបាលកម្ពុជាកំពុងច្បាមយកឱកាសនេះ ដើម្បីត្រៀមខ្លួន សម្រាប់ស្ថានភាពនាពេលអនាគត តាមរយៈការវិនិយោគលើប្រព័ន្ធធានាសន្តិសុខផ្នែកសុខភាព ដើម្បីឱ្យការឆ្លើយតបកាន់តែរឹងមាំ និងកសាងប្រព័ន្ធដែលកាន់តែត្រៀមខ្លួនបានកាន់តែប្រសើរ និងកាន់តែមានភាពធន់។ អង្គការសហប្រជាជាតិសូមវាយតម្លៃខ្ពស់ដល់ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់សុខភាពសាធារណៈ និងបានគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងអំឡុងពេលដែលមានការរាតត្បាតជាសកលកើតមានឡើង តាមរយៈការផ្តល់ជាជំបូន្មានផ្នែកគោលនយោបាយ កិច្ចសហប្រតិបត្តិការបច្ចេកទេស ស្របតាមគោលការណ៍ណែនាំបច្ចេកទេសរបស់អង្គការសុខភាពពិភពលោក ការសម្របសម្រួលដៃគូ និងទីភ្នាក់ងារនានា ការបណ្តុះបណ្តាល និងការអនុវត្តកិច្ចលទ្ធកម្មជាដើម។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួន។

ដើម្បីអាចរកឃើញវីរុស SARS-CoV-2 ដែលជាវីរុសបង្កជំងឺកូវីដ ១៩ ឱ្យកាន់តែទាន់ពេលវេលា ក្នុងនាមជាដៃគូសហការអនុវត្តការងារផ្ទាល់ អង្គការសហប្រជាជាតិបានគាំទ្រដល់ក្រសួងសុខាភិបាល ក្នុងការបង្កើនសមត្ថភាពធ្វើរោគវិនិច្ឆ័យក្នុងមន្ទីរពិសោធន៍ តាមរយៈការផ្តល់ជាជំបូន្មានបច្ចេកទេស យុទ្ធសាស្ត្រស្តីពីការធ្វើតេស្ត ការបណ្តុះបណ្តាល និងការអនុវត្តកិច្ចលទ្ធកម្ម (ក្នុងថវិកាជាង ២ លានដុល្លារ)។ គិតត្រឹមខែកញ្ញា ឆ្នាំ ២០២១ មន្ទីរពិសោធន៍ចំនួន ១២ អាចធ្វើតេស្តចំនួន ១២.000 សំណាកក្នុងមួយថ្ងៃ បើធៀបនឹងស្ថានភាពកាលពីខែកុម្ភៈ ឆ្នាំ ២០២០ ដែលមានមន្ទីរពិសោធន៍តែមួយ និងអាចធ្វើតេស្តបានត្រឹមតែ ៥00 សំណាកក្នុងមួយថ្ងៃ។ បច្ចុប្បន្ននេះ បន្ថែមលើវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈអាចធ្វើតេស្តកំណត់លំដាប់ហ្សែន (genome sequencing) ទាំងស្រុង លើវីរុស SARS-CoV-2។ ការវិនិយោគទាំងនេះនឹងបង្កើនសមត្ថភាពរបស់ប្រទេសកម្ពុជាក្នុងការកំណត់រកពពួកវីរុសបំប្លែងថ្មីនៃវីរុស SARS-CoV-2 ព្រមទាំងមេរោគថ្មីៗដទៃទៀតដែលអាចលេចចេញជាបន្តបន្ទាប់។

អង្គការសហប្រជាជាតិ រួមជាមួយដៃគូអភិវឌ្ឍន៍នានា បានគាំទ្រដល់ក្រសួងសុខាភិបាល ក្នុងការពង្រឹងសមត្ថភាពក្នុងស្រុកក្នុងការកំណត់រកករណីឆ្លងជំងឺកូវីដ១៩ នៅតាមភូមិស្រុក ធ្វើការវាយតម្លៃហានិភ័យ និងឆ្លើយតបចំពោះករណីផ្ទុះជំងឺ។ ក្រុមឆ្លើយតបរហ័ស (RRT) ដែលមានសមាជិកប្រមាណ ៣.000 នាក់ បានទទួលការបណ្តុះបណ្តាលអំពីជំងឺកូវីដ ១៩ កាលពីឆ្នាំ ២០២០ ក្នុងនោះជិត ២០ នាក់បានផ្លាស់ពីតាមខេត្តមកជួយបំពេញការងារដល់ក្រុមតាមរកអ្នកប៉ះពាល់នៅថ្នាក់ជាតិ ចន្លោះពីខែកុម្ភៈ ដល់ខែកក្កដា ឆ្នាំ ២០២១ ដើម្បីជួយផ្តល់ការគាំទ្រដល់ការឆ្លើយតបចំពោះការរាតត្បាតជាសកលនេះ។ ពួកគេបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលផ្ទាល់ ក្នុងអំឡុងពេលអនុវត្តការងាររយៈពេល ៤ ដល់ ៦ សប្តាហ៍នៅនាយកដ្ឋានត្រួតពិនិត្យជំងឺឆ្លង (នៃក្រសួងសុខាភិបាល)។ បច្ចុប្បន្ន សមាជិកក្រុមឆ្លើយតបរហ័ស ដែលបានទទួលការបណ្តុះបណ្តាលទាំងនេះ បំពេញតួនាទីជាប្រធានក្រុមតាមដានរកអ្នកប៉ះពាល់ និងឃ្លាំមើលករណីជំងឺ នៅតាមខេត្តរៀងខ្លួនៗរបស់ពួកគេ។

ខណៈពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានបង្កើនចំនួនមណ្ឌលព្យាបាលជំងឺយ៉ាងឆាប់រហ័សនៅទូទាំងប្រទេស ដែលក្នុងនោះមានទាំងមណ្ឌលព្យាបាលធំៗ តាមតំបន់ផងដែរ អង្គការសហប្រជាជាតិនៅកម្ពុជាបានអនុវត្តកិច្ចលទ្ធកម្ម ដើម្បីទិញសម្ភារផ្គត់ផ្គង់សំខាន់ៗ ដូចជាសម្ភារការពារខ្លួន (ក្នុងថវិកា ១,៨ លានដុល្លារ) ព្រមទាំងឱសថជាសារវ័ន្ត និងបរិក្ខាផ្គត់ផ្គង់អុកស៊ីសែន (ថវិកា ៨២០.000 ដុល្លារ) សម្រាប់ផ្តល់ជូនមណ្ឌលព្យាបាលទាំងនេះ។ លើសពីនេះ អង្គការសហប្រជាជាតិបានជួយដល់កិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពភ្នាក់ងារថែទាំសុខភាពជួរមុខ រាប់បញ្ចូលទាំងអ្នកផ្តល់សេវាសង្គ្រោះបន្ទាន់ផងដែរ អំពីវិធានការគ្រប់គ្រងគ្លីនិក និងការបង្ការនិងត្រួតពិនិត្យការឆ្លងរោគ (IPC)។ អង្គការសហប្រជាជាតិសហការជាមួយនឹងក្រសួងសុខាភិបាល បានប្រមូលផ្តុំអ្នកជំនាញគ្លីនិកក្នុងប្រទេសមកជួបប្រជុំគ្នាជាទៀងទាត់ តាមរយៈកិច្ចប្រជុំតាមប្រព័ន្ធអនឡាញដើម្បីឱ្យពួកគេចែករំលែកបទពិសោធន៍ដល់គ្នាទៅវិញទៅមក ដែលជួយឱ្យអ្នកជំនាញគ្លីនិក ដែលបានទទួលបទពិសោធន៍ក្នុងការគ្រប់គ្រងករណីជំងឺកូវីដ ១៩ ពេលដែលមានការផ្ទុះជំងឺនេះដំបូងៗ អាចជួយផ្តល់ការបំពាក់បំប៉នដល់អ្នកដែលពុំទាន់មានបទពិសោធន៍បែបនេះនៅឡើយ។

អង្គការសហប្រជាជាតិ បានចូលរួមជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញកៀរគរចលនាសហគមន៍ ដែលនេះជាវិធីសាស្ត្រមួយដ៏សំខាន់ និងចាំបាច់ ដើម្បីទប់ទល់នឹងជំងឺកូវីដ ១៩។ កាលពីខែឧសភា និងខែមិថុនា ឆ្នាំ ២០២១ បេសកកម្មរួមគ្នាមួយរវាងក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក បានសម្របសម្រួលកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយនឹងប្រធានមន្ទីរសុខាភិបាលខេត្ត និងអភិបាលខេត្ត ដើម្បីឈ្វេងយល់ពីបទពិសោធន៍របស់អ្នកពាក់ព័ន្ធទាំងនេះ ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ១៩ កំណត់ពីបទពិសោធន៍ជោគជ័យ និងកែសម្រួលផែនការឆ្លើយតប។ របកគំហើញទាំងនេះនាំឱ្យមានការកែសម្រួលអន្តរាគមន៍មិនពាក់ព័ន្ធនឹងការប្រើប្រាស់ឱសថ (NPIs) និងការរៀបចំយុទ្ធនាការថ្នាក់ជាតិ ដើម្បីលើកទឹកចិត្តឱ្យគ្រួសារ និងសហគមន៍ធ្វើការសម្រេចចិត្ត ដែលការពារអាយុជីវិត និងជីវភាពរស់នៅរបស់ពួកគេ។ អង្គការសហប្រជាជាតិក៏បានបណ្តុះបណ្តាល និងជួយដល់សមាជិកសហគមន៍ ក្រុមទ្រទ្រង់សុខភាពភូមិ និងអ្នកដឹកនាំតាមភូមិ តាមសហគមន៍ជនបទ និងសហគមន៍ជនចំណាកស្រុក ដែលងាយរងផលប៉ះពាល់ផងដែរ ដើម្បីបង្កើនចំណេះដឹងអំពីវិធានការការពារជំងឺកូវីដ ១៩ នៅតាមសហគមន៍របស់ពួកគេ ក៏ដូចជាលើកទឹកចិត្តពួកគេទៅចាក់វ៉ាក់សាំងការពារជំងឺកូវីដ ១៩ ដែលជាកត្តារួមចំណែកដល់ការកាត់បន្ថយហានិភ័យនៃការចម្លងនៅក្នុងសហគមន៍។

បើទោះជាកិច្ចខិតខំប្រឹងប្រែងទាំងនេះ ផ្តោតលើជំងឺកូវីដ ១៩ ក៏ដោយ អង្គការសហប្រជាជាតិ ក៏បានសហការជាមួយនឹងដៃគូ និងសហគមន៍ក្នុងប្រទេស ដើម្បីធានាមិនឱ្យមានការអាក់ខានការផ្តល់សេវាថែទាំសុខភាពជាសារវ័ន្ត ដែលជាតម្រូវការ

ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋផងដែរ ដូចជា ការគាំទ្រដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ក្នុងការអនុម័ត និងពង្រីកការអនុវត្តអភិក្រមដែលលក្ខណៈនវានុវត្តន៍ និងប្រសិទ្ធភាព ដើម្បីកាត់បន្ថយការរំខានដល់សេវាដែលជាតម្រូវការចាំបាច់របស់អ្នករស់នៅជាមួយមេរោគអេដស៍ និងសហគមន៍ដែលជាក្រុមប្រឈម ជាដើម។ ការអាក់ខានការផ្តល់សេវាព្យាបាលដល់អ្នករស់នៅជាមួយមេរោគអេដស៍ នៅបន្តស្ថិតក្រោម ១០% ធៀបនឹងពេលមុនមានការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩។ អត្រាគ្របដណ្តប់ការចាក់វ៉ាក់សាំងដល់កុមារនៅទូទាំងប្រទេស សម្រាប់វ៉ាក់សាំងផ្សេងក្រៅពីវ៉ាក់សាំងការពារជំងឺកូវីដ ១៩ នៅបន្តស្ថិតតាមផែនការដែលបានគ្រោងទុក ប៉ុន្តែមានតំបន់ដែលពិបាកទៅដល់ និងសហគមន៍ប្រឈមនឹងហានិភ័យខ្ពស់មួយចំនួន ដែលនៅបន្តមានការគ្របដណ្តប់ក្នុងកម្រិតទាប ដែលទាមទារឱ្យមានការពិនិត្យតាមដាន និងការគាំទ្រឱ្យបានជិតស្និទ្ធដោយផ្ទាល់នៅក្នុងមូលដ្ឋាន។ អង្គការសហប្រជាជាតិ នឹងសហការជាមួយនឹងដៃគូវិស័យសុខាភិបាល ដើម្បីបន្តពិនិត្យតាមដាន និងវិភាគលើនិរន្តរភាពនៃសេវាសុខភាពជាសារវន្តនានា រួមទាំងការគ្របដណ្តប់ ក៏ដូចជានឹងសហការជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងសហគមន៍ ដើម្បីឆ្លើយតបចំពោះឧបសគ្គទាំងនេះ។

ដើម្បីទប់ស្កាត់ករណីនាំចូល និងផ្តល់ការឧបត្ថម្ភគាំទ្រពលករទេសន្តប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍ កម្មវិធីសម្រាប់ឆ្នាំ ២០២០ របស់អង្គការសហប្រជាជាតិបានជួយឱ្យពលករទេសន្តប្រវេសក៍ដែលធ្វើមាតុភូមិនិវត្តន៍ កាន់តែងាយស្រួលចូលរួមអនុវត្តវិធានការការពារជំងឺកូវីដ ១៩ និងទទួលបានការពិនិត្យរកមេរោគនេះនៅតាមច្រកចូល និងមណ្ឌលចត្តាឡីស័ក។ កម្មវិធីនេះបានគាំទ្រដល់ការផ្តល់សេវាសុខភាព និងសង្គមជាសារវន្តដូចជា សេវាថែទាំសុខភាពមាតា និងទារកទើបកើត ការគាំទ្រដល់ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការផ្តល់សេវាសុខភាពផ្លូវចិត្ត និងការគាំទ្រផ្នែកចិត្តសង្គម។ កម្មវិធីនេះក៏បានផ្តល់ព័ត៌មានអំពីវិធានការការពារជំងឺកូវីដ ១៩ និងវិធានការសុខភាពសាធារណៈនានា ដល់ពលករទេសន្តប្រវេសក៍ដែលបានធ្វើមាតុភូមិនិវត្តន៍ ក៏ដូចជាផ្តល់ការណែនាំអំពីរបៀបទទួលបានសេវា សុខភាព និងសង្គមជាសារវន្តផងដែរ។ អង្គការសហប្រជាជាតិក៏បានសហការជាមួយនឹងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីនៅតាមបណ្តោយព្រំដែនអំពីនិតិវិធីគ្រប់គ្រងព្រំដែន ដែលគោរពតាមវិធានការការពារសុខភាព និងអំពីរបៀបកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺឱ្យនៅតិចបំផុតពេលដែលមន្ត្រីទាំងនេះកំពុងបំពេញភារកិច្ចរបស់ខ្លួន។

គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាបានចាក់វ៉ាក់សាំងយ៉ាងហោចណាស់មួយដូសដល់ពលរដ្ឋដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅបានជាង ៩៨% ដែលធ្វើឱ្យប្រទេសនេះក្លាយជាប្រទេសដែលប្រជាពលរដ្ឋបានចាក់វ៉ាក់សាំងច្រើនជាងគេមួយនៅទូទាំងសកលលោក។ ការគាំទ្ររបស់អង្គការសហប្រជាជាតិដល់កិច្ចខិតខំប្រឹងប្រែងនេះ ត្រូវបានរៀបរាប់លម្អិត [នៅក្នុងឯកសារព័ត៌មានអង្គការសហប្រជាជាតិទី ១១ ចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ ២០២១]។ ទោះជាយ៉ាងណាក៏ដោយនេះមិនមែនជាពេលដែលយើងត្រូវបណ្តែតបណ្តោយនោះឡើយ។ វីរុសបំប្លែងថ្មីដែលតា ឆ្លងលឿនជាងពពួកវីរុសបំប្លែងថ្មីមុនៗ និងនាំឱ្យមានការផ្ទុះការឆ្លងជំងឺ និងដាក់សម្ពាធយ៉ាងច្រើនលើសលប់ដល់មន្ទីរពេទ្យនានានៅក្នុងប្រទេសផ្សេងទៀត។ ការបន្តឆ្លងជំងឺនាពេលនេះអាចនាំឱ្យមានការលេចចេញនូវពពួកវីរុសបំប្លែងថ្មី ដែលអាចបង្កការគម្រាមកំហែងនៅគ្រប់ពេលវេលាទាំងអស់។ អង្គការសហប្រជាជាតិជំរុញឱ្យមានការបន្តវិនិយោគលើប្រព័ន្ធឃ្លាំមើល និងឆ្លើយតបនៅថ្នាក់ខេត្ត ដើម្បីផ្តល់លទ្ធភាពឱ្យខេត្តរកឃើញករណីនានាបានកាន់តែឆាប់រហ័ស និងឆ្លើយតបចំពោះចង្កោមករណី ដោយប្រើប្រាស់វិធានការផ្តោតចំគោលដៅផ្ទាល់នៅនឹងកន្លែងដែលមានករណីផ្ទុះ ដែលនឹងជួយកាត់បន្ថយការរំខានផ្នែកសេដ្ឋកិច្ច និងសង្គមឱ្យនៅតិចជាអប្បរមា។ ការវិនិយោគនេះគួរបញ្ចូលការបង្កើនភាពអាចរកបាននៃទិន្នន័យ និងការកែកម្មការគ្រប់គ្រងទិន្នន័យនៅតាមខេត្ត ដោយមានការបែងចែកទិន្នន័យតាមប្រភេទលម្អិត ដើម្បីវាយតម្លៃពិវិសាលភាពគ្របដណ្តប់នៃសេវាសុខភាពជាសារវន្ត ជាពិសេសសម្រាប់បុគ្គលដែលប្រឈមនឹងហានិភ័យងាយរងគ្រោះ និងមានឱកាសតិចតួច។ អង្គការសហប្រជាជាតិលើកទឹកចិត្តឱ្យមានការផ្តល់

អាទិភាពដល់កិច្ចខិតខំប្រឹងប្រែងនានា ដើម្បីធានាយ៉ាងណាឱ្យក្រុមពលរដ្ឋដែលងាយរងគ្រោះ ចាស់ជរា និងអ្នកដែលមានបញ្ហាសុខភាពប្រចាំកាយ ១០០% បានទទួលការចាក់វ៉ាក់សាំងពេញលេញ ដើម្បីសង្គ្រោះអាយុជីវិតដែលពុំអាចជំនួសបាន និងការពារប្រព័ន្ធសុខាភិបាល និងមន្ទីរពេទ្យមិនឱ្យទទួលរងសម្ពាធខ្លាំងពេក។ អង្គការសហប្រជាជាតិជំរុញឱ្យមានការបន្តផ្តល់ការគាំទ្រដល់ការអប់រំផ្សព្វផ្សាយអំពីហានិភ័យ និងការបំផុសចលនាសហគមន៍ ដើម្បីការពារផលចំណេញដែលទទួលបានតាមរយៈការផ្តល់ភាពអង់អាចឱ្យគ្រួសារ និងសហគមន៍ធ្វើការសម្រេចចិត្តដែលជួយសង្គ្រោះអាយុជីវិត និងជីវភាពរស់នៅរបស់ពួកគេ។

អង្គការសហប្រជាជាតិអំពាវនាវឱ្យមានការគោរពគ្រប់សិទ្ធិមនុស្សទាំងអស់ ដើម្បីឱ្យការឆ្លើយតបផ្នែកសុខភាពសាធារណៈទទួលបានជោគជ័យ។ ខណៈដែលការឆ្លើយតបពីវិស័យសុខាភិបាល ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺកូវីដ ១៩ ចំពោះមុខ គឺជារឿងដែលមានសារៈសំខាន់ អង្គការសហប្រជាជាតិជំរុញឱ្យមានការអនុវត្តយុទ្ធសាស្ត្រដែលឈរលើគោលការណ៍សិទ្ធិមនុស្ស និងយេនឌ័រជាផ្នែកមួយនៃការគាំទ្រដល់ការលើកកម្ពស់សុខភាពសាធារណៈ។ អង្គការសហប្រជាជាតិអំពាវនាវឱ្យអាជ្ញាធរលើកកម្ពស់សមភាព និងការមិនរើសអើង ដែលមានដូចជាការឆ្លើយតបចំពោះឧបសគ្គដែលកើតមានកន្លងមកដែលធ្វើឱ្យប៉ះពាល់ដល់ការទទួលបានសេវាសុខភាព និងរៀបចំសេវាព្យាបាល និងសេវាសុខភាពនានាឱ្យបានដល់អ្នកដែលពុំមានមធ្យោបាយសម្រាប់បង់ថ្លៃសេវាទាំងនេះ។ អង្គការសហប្រជាជាតិបន្តអំពាវនាវឱ្យអាជ្ញាធរកសាងគោលនយោបាយសុខភាពសាធារណៈជាថ្មី ដើម្បីឈានទៅពង្រីកគ្របដណ្តប់នៃសេវាសុខភាពជាសកល ដែលឈរមូលដ្ឋានលើសិទ្ធិមនុស្សដែលក្នុងនោះមនុស្សគ្រប់គ្នាបានទទួលភាពអង់អាច ទទួលបានព័ត៌មានត្រឹមត្រូវ និងមានឱកាសចូលរួម។

សុខភាពគឺជាការវិនិយោគដែលគេមិនគួរចាត់ទុកថាជាចំណាយថ្លៃដើមនោះឡើយ។ យើងបានរៀនពីការរាតត្បាតជាសកលនៃជំងឺកូវីដ ១៩ ថាសុខភាពគឺជាផ្នែកមួយដ៏សំខាន់ និងពុំអាចញែកចេញពីផ្នែកដទៃទៀតនៅក្នុងសង្គម ពោលមិនមែនជាសេវាប្រណិត ដែលទាល់តែអ្នកមានលទ្ធភាពទើបអាចទទួលបាននោះឡើយ។ ប្រសិនបើសុខភាពប្រឈមនឹងហានិភ័យអ្វីៗគ្រប់បែបយ៉ាងក៏ប្រឈមនឹងហានិភ័យដែរ រដ្ឋាភិបាលត្រូវចាត់ទុកការពង្រឹងសុវត្ថិភាពផ្តល់សេវាថែទាំសុខភាព និងប្រព័ន្ធសុខាភិបាលសាធារណៈថាជាអាទិភាព និងត្រូវវិនិយោគនាពេលនេះ ដើម្បីអនាគតកាន់តែមានសុវត្ថិភាព និងកាន់តែមានសុខភាពល្អប្រសើរ។ ដើម្បីកសាងឡើងវិញឱ្យរឹតតែប្រសើរជាងមុន រដ្ឋាភិបាលក៏ត្រូវច្បាមយកឱកាសនេះ ដើម្បីអនុវត្តគោលនយោបាយបដិវត្តកម្ម ដូចជាការពង្រីកការគ្របដណ្តប់សេវាសុខភាពជាសកល និងការផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាពដល់សេវាថែទាំសុខភាព ដើម្បីធានាឱ្យប្រព័ន្ធសុខាភិបាលមានភាពធន់។ អង្គការសហប្រជាជាតិសូមវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលដែលចាត់ទុកចំណុចទាំងនេះជាអាទិភាព ហើយនឹងបន្តផ្តល់ការគាំទ្រដល់រដ្ឋាភិបាលក្នុងការសម្រេចគោលដៅនេះ។

###

ឯកសារព័ត៌មានស្តីពីការឆ្លើយតបចំពោះជំងឺកូវីដ ១៩ របស់អង្គការសហប្រជាជាតិនៅកម្ពុជា គឺជាឯកសារផ្លូវការណ៍របស់អង្គការសហប្រជាជាតិ ដែលមានគោលបំណងផ្សព្វផ្សាយជូនប្រព័ន្ធផ្សព្វផ្សាយ និងដៃគូដទៃទៀត។ ឯកសារទាំងនេះត្រូវបានរៀបចំដោយការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។